នស/រកម/០៨៩៧/០៣

រដ្ឋសភា
ចូល លេខ ១៥២០
ថ្ងៃទី ១១.៨.៩៧ ម៉ោង ៣
បញ្ជូនទៅ ...

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៨៩៧.១៨៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស.រកម.០១៩៦.២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង ឯកឧត្តម ថោ ប៉េងលាត ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៣
- តាមសេចក្តីក្រាបបង្គំទូលរបស់ឯកឧត្តមអ៊ឹង ហួត នាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងការប្តូរប្រាក់

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះអនុវត្តចំពោះរាល់ប្រតិបត្តិការរូបិយប័ណ្ណនិងជាទូទៅគឺ រាល់ប្រតិបត្តិការដែលប្រព្រឹត្តឡើងរវាងនិវាសជននិងអនិវាសជនទាក់ទងទៅនឹង :

-ការទូទាត់ពាណិជ្ជកម្ម

-ការផ្ទេរប្រាក់ ឬ

-ចលនានៃដើមទុន ដោយរាប់បញ្ចូលទាំងការវិនិយោគផង ។

**មាត្រា ២.-**

ត្រូវចាត់ទុកជារូបិយប័ណ្ណ សំរាប់ការអនុវត្តច្បាប់នេះ :

-មធ្យោបាយទូទាត់ឬមូលប័ត្រ ជារូបិយវត្ថុបរទេស

-មាសមិនទាន់កែច្នៃឬលោហធាតុមានតំលៃដទៃទៀតមិនទាន់កែច្នៃនិងត្បូងថ្មមានតំលៃមិនទាន់កែច្នៃ ។

**មាត្រា ៣.-**

ត្រូវចាត់ទុកជានិវាសជន :

-រូបវន្តបុគ្គលទាំងឡាយដោយពុំគិតពីសញ្ជាតិ ដែលមានសកម្មភាពចំបងឬមានលំនៅឋានចំបងនៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ ( ១៨២ថ្ងៃ ) ឡើងទៅ វៀរលែងតែមន្ត្រីបរទេស ដែលបំពេញបេសកកម្មការទូតឬបេសកជនប្រហាក់ប្រហែល

-នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសនិងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់នីតិបុគ្គលនៃច្បាប់ក្រៅប្រទេស

-គ្រប់មន្ត្រីរាជការខ្មែរបំពេញភារកិច្ចនៅបរទេស ដោយឥតគិតពីរយៈពេលនៃការស្នាក់នៅ ។

**មាត្រា ៤.-**

ត្រូវចាត់ទុកជាអនិវាសជន :

-រូបវ័ន្តបុគ្គលសញ្ជាតិខ្មែរ ដែលមានសកម្មភាពចំបងឬលំនៅឋានចំបងនៅបរទេស ចាប់ពីមួយរយប៉ែតសិបពីរថ្ងៃ ( ១៨២ថ្ងៃ ) ឡើងទៅ

-រូបវ័ន្តបុគ្គលបរទេសដែលមានសកម្មភាពចំបងឬលំនៅឋានចំបងនៅព្រះរាជាណាចក្រកម្ពុជា តិចជាងមួយរយប៉ែតសិបពីរថ្ងៃ ( ១៨២ថ្ងៃ )

-នីតិបុគ្គលនៃច្បាប់ក្នុងប្រទេសដែលមានទីតាំងនៅបរទេសនិងសាខានៅបរទេសរបស់នីតិបុគ្គលនៃច្បាប់ក្នុងប្រទេស

-មន្ត្រីបរទេសដែលបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជាឬបេសកជនប្រហាក់ប្រហែល ។

# ជំពូកទី ២

## អន្តរការីយកម្មធនាគារ

**មាត្រា ៥.-**

១-រាល់ប្រតិបត្តិការប្តូរប្រាក់តាមរបៀបលេខនានាដោយមានរាប់បញ្ចូលការទិញនិងការលក់រូបិយប័ណ្ណលើផ្សារប្តូរប្រាក់ផង ការផ្ទេរប្រាក់ ការទូទាត់ក្រៅប្រទេសគ្រប់ប្រភេទក៏ដូចជាចលនានៃដើមទុនជារូបិយប័ណ្ណ ឬជារូបិយវត្ថុជាតិរវាងកម្ពុជានិងប្រទេសក្រៅ ឬរវាងនិវាសជននិងអនិវាសជន អាចប្រព្រឹត្តទៅដោយសេរី ប៉ុន្តែប្រតិបត្តិការទាំងនោះ ត្រូវតែអនុវត្តដោយឆ្លងតាមអន្តរការីប្រតិស្រុតិ ។

២-មានតែធនាគារដែលមានទីតាំងជាប្រចាំនៅព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ដែលត្រូវបានចាត់ទុកជាអន្តរការីប្រតិស្រុតិ ។

៣-អន្តរការីប្រតិស្រុតិ ក្រោមល័ក្ខខ័ណ្ឌដែលមានកំណត់ក្នុងបទបញ្ជា ត្រូវបង្គិឱ្យផ្តល់ជូនធនាគារកណ្តាលជាទៀងទាត់ នូវរបាយការណ៍តាមកាលកំណត់ តាមប្រភេទនៃប្រតិបត្តិការផ្ទេរប្រាក់ឬការទូទាត់និងចលនានៃដើមទុនចេញ និងចូលដែលបានអនុវត្តរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសក្រៅទៅតាមរយៈពេលដែលនឹងកំណត់ដោយធនាគារកណ្តាល ។

៤-អន្តរការីប្រតិស្រុតិដែលធ្វើការនាំចេញសាច់ប្រាក់ជារូបិយប័ណ្ណ ត្រូវធ្វើប្រតិវេទន៍ជាមុនជូនធនាគារកណ្តាល ។

៥-អាជីវករប្តូរប្រាក់ដល់ដៃដែលមានទីតាំងអចល័តឬចល័តអាចធ្វើសកម្មភាពប្តូរប្រាក់បានលុះត្រាតែបានទទួលការអនុញ្ញាតជាមុនពីធនាគារកណ្តាល ។

**មាត្រា ៦.-**

ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជាសំរាប់រយៈពេលយ៉ាងយូរ ៣ខែ ដើម្បីកំណត់ល័ក្ខខ័ណ្ឌបណ្តោះអាសន្នខ្លះចំពោះសកម្មភាពរបស់អន្តរការីប្រតិស្រុតិ ជាអាទិ៍ចំពោះប្រតិបត្តិការដែលមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ ឬស្ថានភាពរូបិយប័ណ្ណរបស់ខ្លួនឬការឱ្យខ្ចីជារូបិយវត្ថុជាតិទៅអនិវាសជន ។ ក្នុងករណីត្រូវបន្តទៀតនោះ ធនាគារកណ្តាលសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៧.-**

និវាសជនអាចកាន់រក្សាទុកនូវរូបិយប័ណ្ណដោយសេរីទាំងទម្រង់ ទាំងទីកន្លែងនៅក្នុងប្រទេស។ ក្នុងករណីមានវិបត្តិពីការប្តូរប្រាក់ ធនាគារកណ្តាលអាចចេញបទបញ្ជាសម្រាប់រយៈពេលយ៉ាងយូរ ៣ខែ ដើម្បីផ្អាកមិនឱ្យអនុវត្តបទប្បញ្ញត្តិនេះជាបណ្តោះអាសន្ន ។ ក្នុងករណីត្រូវបន្តទៀតនោះ ធនាគារកណ្តាលសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើកសំណើសុំការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ៣

## ប្រតិបត្តិការចរន្ត

**មាត្រា ៨.-**

អ្នកនាំចេញឬអ្នកនាំចូលទំនិញឬសេវា ត្រូវធ្វើការទូទាត់តាមរយៈអន្តរការីប្រតិស្រុតិនូវប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនជាមួយប្រទេសក្រៅ ។

**មាត្រា ៩.-**

ធនាគារកណ្តាលអាចទាមទារឱ្យអន្តរការីប្រតិស្រុតិបង្ហាញនូវសក្ខីប័ត្រធនាគារវិកយ្ប នៅពេលដែលដាក់ពាក្យសុំទិញរូបិយប័ណ្ណដើម្បីទូទាត់ការនាំចូល និងនៅពេលក្រោយមកទៀតនូវសក្ខីប័ត្ររដ្ឋបាលផ្សេងៗទៀតដែលបញ្ជាក់ថា ទំនិញបាននាំចូលមកក្នុងប្រទេសរួចហើយ ។

**មាត្រា ១០.-**

ចាប់តាំងពីពេលធ្វើបេឡានិច័យ ប្រាក់ចំណូលដែលបានមកពីការនាំចេញទំនិញឬសេវា ត្រូវបញ្ចូលក្នុងខ្ទង់ឥណទាននៃគណនីរបស់អ្នកនាំចេញ ដែលមានបើកនៅធនាគារវិកយ្បស្របតាមមាត្រា៨ នៃច្បាប់នេះ។

**មាត្រា ១១.-**

មូលនិធិបដិភាគជារូបិយវត្ថុជាតិ ដែលបានមកពីការធ្វើពាណិជ្ជកម្មក្នុងប្រទេសនូវទំនិញនាំចូល ក្នុងក្របខ័ណ្ឌការខ្ចីប្រាក់ពីក្រៅឬជាអំណោយ ត្រូវបង់ចូលខ្ទង់ឥណទាននៃគណនីរបស់រតនាគារជាតិ ដែលបើកនៅធនាគារកណ្តាល ទៅតាមបែបបទដែលនឹងត្រូវកំណត់តាមកិច្ចព្រមព្រៀងរវាងរតនាគារជាតិនិងធនាគារកណ្តាល ។

**មាត្រា ១២.-**

រាល់ការនាំចេញឬការនាំចូលមាសមិនទាន់កែច្នៃ ត្បូងថ្មមានតំលៃមិនទាន់កែច្នៃឬលោហធាតុមានតំលៃមិនទាន់កែច្នៃដទៃទៀត អាចដំណើរការដោយសេរី ស្របតាមចំណុច ១ មាត្រា ៥ នៃច្បាប់នេះ ប៉ុន្តែត្រូវធ្វើប្រតិវេទន៍ជាមុននៅធនាគារកណ្តាល បើចំនួនទំនិញនៃប្រតិបត្តិការនីមួយៗមានតំលៃស្មើឬលើសពីមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិក។

**មាត្រា ១៣.-**

ការនាំចេញឬការនាំចូលដោយអ្នកដំណើរនូវមធ្យោបាយទូទាត់ជារូបិយប័ណ្ណដែលមានទឹកប្រាក់ស្មើឬលើសពីមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិក ឬជារូបិយវត្ថុជាតិដែលមានតំលៃសមមូលនឹងមួយម៉ឺន ( ១០.០០០ ) ដុល្លារអាមេរិកឬច្រើនជាងនេះ ត្រូវតែធ្វើប្រតិវេទន៍ចំពោះមន្ត្រីគយនៅពេលឆ្លងកាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ។

សាច់ប្រាក់ចាប់តាំងពីកំរិតមួយដែលកំណត់ដោយបទបញ្ជារបស់ធនាគារកណ្តាល អ្នកនាំចេញត្រូវដាក់ជូនធនាគារកណ្តាលពិនិត្យជាមុន មុននឹងធ្វើការនាំចេញ ។

ជារៀងរាល់ខែ ទីចាត់ការគយនិងរដ្ឋាករត្រូវបញ្ជូនបញ្ជីនៃប្រតិវេទន៍ដូចបានកំណត់ខាងលើទៅធនាគារកណ្តាល ។

## ជំពូកទី ៤

## ការវិនិយោគ ចលនានៃដើមទុន

**មាត្រា ១៤.-**

ចលនានៃដើមទុនទាក់ទងនឹងការវិនិយោគបរទេសនៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥.-**

ក្នុងករណីដែលការជំរះបញ្ជីនៃការវិនិយោគបរទេសបានប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ផលដែលបានមកពីការជំរះបញ្ជីនោះនឹងត្រូវផ្ទេរបានដោយសេរី ។

**មាត្រា ១៦.-**

ការធ្វើវិនិយោគនៃនិវាសជននៅបរទេស ត្រូវធ្វើប្រតិវេទន៍ជាមុនដល់ធនាគារកណ្តាល បើទឹកប្រាក់មានចំនួនស្មើឬលើសពីមួយសែន ( ១០០.០០០) ដុល្លារអាមេរិក ។

**មាត្រា ១៧.-**

ការផ្ទេរប្រាក់ទាក់ទងនឹងការធ្វើវិនិយោគឬការជំរះបញ្ជីនៃការធ្វើវិនិយោគ ត្រូវធ្វើតាមរយៈអន្តរការីប្រតិស្រុតិដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។ អន្តរការីប្រតិស្រុតិ ត្រូវធ្វើរបាយការណ៍ជូនធនាគារកណ្តាលជាក្រោយលើទឹកប្រាក់ធ្វើប្រតិបត្តិការម្តងៗមានចំនួនស្មើ ឬលើសពីមួយសែន (១០០.០០០) ដុល្លារអាមេរិក ។

## ជំពូកទី ៥

### ចលនានៃដើមទុនផ្សេងៗ

**មាត្រា ១៨.-**

ការឱ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ ដោយរាប់បញ្ចូលទាំងឥណទានពាណិជ្ជកម្មផងរវាងនិវាសជននិងអនិវាសជនអាចប្រព្រឹត្តទៅដោយសេរី ឱ្យតែការខ្ចីនិងការសងវិញ ធ្វើតាមរយៈអន្តរការីប្រតិស្រុតិ ។

**មាត្រា ១៩.-**

ចលនានៃដើមទុនដែលជាលទ្ធផលនៃប្រតិបត្តិការទាំងនោះ (ការទូទាត់ថ្លៃទំនិញឬសេវានាំចូលនិងនាំចេញ ការផ្ទេរប្រាក់ ការវិនិយោគ ការឱ្យប្រាក់គេខ្ចីនិងការខ្ចីប្រាក់ពីគេ) ត្រូវបញ្ចូលក្នុងរបាយការណ៍ធនាគារជាប្រចាំ តាមការកំណត់ដែលមានចែងក្នុងចំណុច ៣ មាត្រា ៥ នៃច្បាប់នេះ ។ ចលនានៃដើមទុនទាំងនោះត្រូវកត់ត្រាតាមប្រភេទប្រតិបត្តិការនីមួយៗ ហើយត្រូវគោរពដល់ការសម្ងាត់វិជ្ជាជីវៈ ។

# ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ២០.-**

អន្តរការីប្រតិស្រុតិមានភារៈ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ដោយប្រុងប្រយ័ត្ននូវការគោរពបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ឬដែលមានចែងក្នុងបទបញ្ជាទាំងឡាយនៃធនាគារកណ្ដាល ដើម្បីអនុវត្តប្រតិបត្តិការដែលខ្លួនបានធ្វើដោយផ្ទាល់ឬដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ។

អន្តរការីប្រតិស្រុតិណាដែលមិនគោរពតាមបទប្បញ្ញត្តិនៃវាក្យខណ្ឌខាងលើ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ២១.-**

ជនណាប្រព្រឹត្តល្មើសនឹងចំណុច ៣ ឬ ចំណុច ៤ ឬ ចំណុច ៥ នៃមាត្រា៥ ឬប្រព្រឹត្តល្មើសនឹងមាត្រា១៧ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់ ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយលានរៀល ( ១.០០០.០០០ រៀល ) ដល់ដប់លានរៀល ( ១០.០០០.០០០ រៀល ) ឬផ្តន្ទាទោសណាមួយក្នុងទោសទាំងពីរនេះ ។

**មាត្រា ២២.-**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា១១ ឬ វាក្យខណ្ឌទី១ នៃមាត្រា១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងដប់ភាគរយ ( ១០ភាគរយ ) នៃទឹកប្រាក់ល្មើស ។

**មាត្រា ២៣.-**

ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១២ ឬមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងម្ភៃភាគរយ ( ២០ភាគរយ ) នៃទឹកប្រាក់ល្មើស ។

**មាត្រា ២៤.-**

ជនណាប្រព្រឹត្តល្មើសនឹងវាក្យខណ្ឌទី ២ នៃមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល ( ១.០០០.០០០ រៀល ) ដល់ដប់លានរៀល ( ១០.០០០.០០០ រៀល ) ។ រីឯវត្ថុតាងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

មាត្រា ២៥.–

ជនណាប្រព្រឹត្តល្មើសនឹងចំណុច ១ មាត្រា ៥ ឬ មាត្រា ៨ ឬមាត្រា ១៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ស្មើនឹងហាសិបភាគរយ ( ៥០ភាគរយ ) នៃចំនួនប្រាក់ល្មើស ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

មាត្រា ២៦.–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ហត្ថលេខា | ហត្ថលេខា |
| **អ៊ុង ហួត** | **ហ៊ុន សែន** |

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២

អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

**ជា ចាន់តូ**

លេខ: ១៥៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ១៩៩៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]